**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**

ក្រសួងបរិស្ថាន

លេខៈ ៤០៥ ប្រ.ក ប.ស្ត

រាជធានីភ្នំពេញ. ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០០៦

# ប្រកាស

## ស្តីពី ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងសំរបសំរួលការងារអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងសារធាតុគីមី

=======================

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងលិខិតលេខ ៥៥៥៨ អជ.កបទ-សអ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៦ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងលិខិតលេខ ១៣២៦ សជណ.កស ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៤៧៩១ កសក ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០០៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងលិខិតលេខ ១៦៥៩ ឧរថ.បឧ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៦ និងលិខិតលេខ ១៨១៥ ឧរថ.បឧ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងលិខិតលេខ ០១២ អបស/កស ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៦ របស់ក្រសួងសុខាភិបាល

- យោងលិខិតលេខ ១៩០៨ សក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០៦ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងលិខិតលេខ ១៩០៨ MoC / SM2006 ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៦ របស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិតលេខ ៤៣៩ សជណ.អទច ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០០៦ របស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ ១០៣៦ ក.ក.ប.វ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងលិខិតលេខ ២១៧ សជណ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ
- យោងលិខិតលេខ ៧៨២ គរ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០០៦ របស់ទីចាត់ការគយនិងរដ្ឋាករ
- យោងលិខិតលេខ ៧១៧ ឆត.ស ក្រ ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាក្រុងភ្នំពេញ
- យោងលិខិតលេខ ០៨-០១៤/០៦ វសអកក.រប ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០០៦ របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- យោងលិខិតលេខ ៦៦២/២០០៦ សភភព ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៦ របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- យោងលិខិតចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០០៦ របស់អង្គការម្លប់បៃតង
- យោងលិខិតលេខ ០១៦១៩ សសកក ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ របស់សហព័ន្ធសហជីពកម្មករកម្ពុជា
- ពិនិត្យលើភាពចាំបាច់ក្នុងការបង្កើនប្រសិទ្ធិភាពការគ្រប់គ្រងសារធាតុគីមីនៅក្នុងក្របខ័ណ្ឌជាតិ ។

## **សំរេច**

**ប្រការ ១** : បង្កើត **ក្រុមការងារបច្ចេកទេសអន្តរក្រសួងសំរបសំរួលការងារអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងសារធាតុគីមី** ដើម្បីធានាបាននូវការសំរបសំរួលរាល់សកម្មភាពក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធទៅនឹងការចូលរួមអនុវត្តអនុសញ្ញា សន្ធិសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលទាក់ទងទៅនឹងបញ្ហានិងការគ្រប់គ្រងសារធាតុគីមីក្នុងគោលដៅទប់ស្កាត់ភាពគ្រោះថ្នាក់ដែលបង្កដោយសារធាតុគីមីទៅលើសុខភាពសាធារណៈ និងបរិស្ថាន ។

**ប្រការ ២** : សមាសភាពនៃក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះរួមមាន :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ខៀវ មុត | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ប្រធាន |
| ២- | ឯកឧត្តម ឡុញ ហ៊ាល | អគ្គនាយកបច្ចេកទេស | អនុប្រធាន |
| ៣- | លោក ឡុង រិទ្ធីរក្ស | អគ្គនាយករងបច្ចេកទេស | អនុប្រធាន |
| ៤- | លោក ហេង ណារ៉េត | ប្រធាននាយកដ្ឋាន ក្រសួងបរិស្ថាន | លេខាធិការ |
| ៥- | លោក សូ សិង្ហា | អនុប្រធាននាយកដ្ឋាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦- | លោក ហាក់ សីលា | ប្រធានការិយាល័យ នាយកដ្ឋានកសិកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- | លោក ប៊ុនធូន ស៊ីម៉ូណា | អនុប្រធានការិយាល័យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- | លោក សុក សារូ | អនុប្រធានការិយាល័យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

Cm

| | | | |
|---|---|---|---|
| ៩- | លោក វិចទ័រ ហ្សូនា | អគ្គនាយករង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០- | លោក ប៊ី ពិទូរ្យ | អនុប្រធាននាយកដ្ឋាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១- | លោក ចាន់ បូរិទ្ធ | អនុប្រធាននាយកដ្ឋាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១២- | លោកស្រី ប្រាក់ ពិសិដ្ឋរង្សី | ប្រធាននាយកដ្ឋាន ក្រសួងសុខាភិបាល | សមាជិក |
| ១៣- | លោកស្រី ជួន ចន្ទោភាស | នាយករងមន្ទីរពិសោធន៍ជាតិ ក្រសួងសុខាភិបាល | សមាជិក |
| ១៤- | លោក ស្រី សិរីវឌ្ឍនី | អនុប្រធាននាយកដ្ឋាន ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥- | លោក ហម សុវណ្ណា | អនុប្រធានការិយាល័យ ក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ១៦- | លោក ឃ្លោក ជួន | អនុប្រធាននាយកដ្ឋាន ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៧- | លោក សារឿន កេសារា | ប្រធានការិយាល័យ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៨- | លោក អ៊ឹម វិមល | នាយរងការិយាល័យ ក្រសួងទេសចរណ៍ | សមាជិក |
| ១៩- | លោក វេជ្ជបណ្ឌិត យី គន្ធិដ្ឋា | អនុប្រធាននាយកដ្ឋានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២០- | លោក នូ សារ៉ារិទ្ធ | ប្រធានការិយាល័យ ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ២១- | លោក ជា ហាក់ | ប្រធានការិយាល័យ ទីចាត់ការគយនិងរដ្ឋាករ | សមាជិក |
| ២២- | លោក ប៊ូរ ប៊ុនណារ៉ា | ជំនួយការការិយាល័យ ទីចាត់ការគយនិងរដ្ឋាករ | សមាជិក |
| ២៣- | លោក សៅ គុនឆុន | អភិបាលរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ | សមាជិក |
| ២៤- | បណ្ឌិត ព្រាប វិសារទោ | ប្រធានការិយាល័យវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ២៥- | លោក យឹម ម៉ុងតឿន | សាស្ត្រាចារ្យដេប៉ាតឺម៉ង់បរិស្ថាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ២៦- | លោក ជែក វិមានភក្តី | ប្រធានគ្រប់គ្រងគំរោងសាលារៀននិងបរិស្ថាន អង្គការមួបបៃតង | សមាជិក |
| ២៧- | លោក សោម អូន | ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា | សមាជិក |

**ប្រការ ៣** : ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះមានតួនាទី និងភារៈកិច្ចដូចខាងក្រោម :

- បំពេញការងារជាសេនាធិការជូនថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធ ក្នុងការសិក្សាពីកាតព្វកិច្ចនិងតម្រូវការរបស់ជាតិ លើការចូលរួមអនុវត្តន៍អនុសញ្ញា សន្ធិសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី សំរាប់ជាមូលដ្ឋាននៃការធ្វើសេចក្តីសំរេចចិត្ត និងជំរុញការចូលរួមអនុវត្តន៍ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។
- លើកស្នើនូវគោលនយោបាយជាតិ ឬផែនការជាតិលើការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាព ជូនថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធពិនិត្យសំរេច ។
- ចូលរួមផ្តល់យោបល់លើរាល់សេចក្តីព្រៀងលិខិតបទដ្ឋានច្បាប់ និងផែនការសកម្មភាពជាតិ ដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ។
- សិក្សា និងវាយតំលៃពីបញ្ហា និងពីចំនុចខ្វះខាតលើការគ្រប់គ្រងសារធាតុគីមីនៅក្នុងក្របខ័ណ្ឌជាតិ និងរាយការណ៍ជូនថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធជ្រាបពីតំរូវការចាំបាច់បន្ថែមសំរាប់ឈានទៅគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាព ។

- ប្រមូល ឬទទួលយកព័ត៌មានពាក់ព័ន្ធទៅនឹងបញ្ហាសារធាតុគីមីក្នុងក្របខ័ណ្ឌអន្តរជាតិ តំបន់ ឬជាតិ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំតាមស្ថាប័ន ឬអង្គភាពពាក់ព័ន្ធជ្រាប ឬដើម្បីចាត់ជាវិធានការ ។
- ជួយសំរបសំរួលដល់ការងារទំនាក់ទំនងរវាងស្ថាប័នពាក់ព័ន្ធ និងផ្លាស់ប្តូរព័ត៌មានក្នុងចំណោមសមាជិកក្រុមការងារ លើកបញ្ហាដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ។
- ជួយសំរបសំរួលដល់បណ្តាគំរោង កម្មវិធី និងសកម្មភាពស្រាវជ្រាវនានាក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធការចូលរួមអនុវត្តន៍អនុសញ្ញា សន្ធិសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ។

**ប្រការ ៤** : សមាជិកនៃក្រុមការងារបច្ចេកទេសអន្តរក្រសួងទាំងអស់ ត្រូវអនុវត្តតាមភារៈកិច្ចដូចមានចែងក្នុងប្រការ ៣ ខាងលើ និងត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួង ។

**ប្រការ ៥** : ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍ មានភារៈកិច្ចរៀបចំការប្រជុំក្រុមការងារ ធ្វើរបាយការណ៍កិច្ចប្រជុំ និងផ្តល់ព័ត៌មានពាក់ព័ន្ធការអនុវត្តន៍អនុសញ្ញា សន្ធិសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ជូនសមាជិកក្រុមការងារ ។

**ប្រការ ៦** : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ នាយកនៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន និងសាមីខ្លួនត្រូវអនុវត្តតាមសេចក្តីប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវិទ្យា

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ដូចក្នុងប្រការ ៦
- ឯកសារ-កាលប្បវត្តិ